

# ការងារអភិវឌ្ឍន៍ ប្រកបដោយការច្នៃប្រឌិត និងចីរភាព

*ភាពក្រីក្រ គឺជាឫសគល់នៃបញ្ហាជាច្រើនដូចជា ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកខុសច្បាប់។ នៅក្នុងប្រទេសកម្ពុជា បញ្ហានេះជារឿយៗតែងតែកើតមានឡើងនៅតាមសហគមន៍ជនបទក្រីក្រ ដែលមនុស្សភាគច្រើនកំពុងរស់នៅក្រោម ឬស្ថិតនៅចំពីលើខ្សែបន្ទាត់នៃភាពក្រីក្រ។ ជាការពិតណាស់ ករណីជាក់ស្តែងដូចដែលមាននៅតាមតំបន់គោលដៅរបស់ គម្រោងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ របស់អាយស៊ីស៊ី នៅក្នុងស្រុកព្រះស្តេច ដែលយុវជនភាគច្រើនបាននិងកំពុងតែធ្វើការចំណាកស្រុកស្របច្បាប់ និងខុសច្បាប់ ដើម្បីស្វែងរកឱកាសការងារនៅក្នុងប្រទេសជិតខាង ដូចជានៅក្នុងប្រទេសថៃផងដែរ។ ដោយសារតែមានការព្រួយបារម្ភនេះកាន់តែខ្លាំងឡើងនោះ អាជ្ញាធរមូលដ្ឋានបានស្វាគមន៍ដល់ គម្រោងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ សម្រាប់កម្មវិធីផ្សព្វផ្សាយរបស់ពួកគេ ដែលផ្តោតទៅលើការបណ្តុះបណ្តាលស្តីពីការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដែលមានសុវត្ថិភាព និងជំនាញទន់ផ្សេងៗទៀត ទៅដល់សិស្សានុសិស្សនៅសាលារដ្ឋ។*

គម្រោងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ របស់អាយស៊ីស៊ី បានចាប់ផ្តើមធ្វើការជាមួយសាលារដ្ឋនៅក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង ដើម្បីលើកកម្ពស់សិស្សានុសិស្សឲ្យមានការយល់ដឹងស្តីពី របៀបការពារខ្លួននឹងអ្នកដទៃ ពីគ្រោះថ្នាក់ណាមួយដែលបានបង្កឡើង ដោយសារការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកខុសច្បាប់។ ហេតុផលដែលក្រុមការងាររបស់ គម្រោងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ បានធ្វើការចូលរួមសហការជាមួយសាលារដ្ឋនោះ គឺដោយសារតែមានការលំបាកក្នុងការប្រមូលសិស្សានុសិស្ស ឲ្យចូលរួមក្នុងសកម្មភាពរបស់គម្រោង ក្រៅម៉ោងសិក្សារបស់ពួកគេ។ នេះគឺដោយសារតែសិស្សភាគច្រើនរវល់ជួយឪពុកម្តាយរបស់ពួកគេ នៅវាលស្រែ ហើយសិស្សដទៃផ្សេងទៀតជាប់រវល់ធ្វើកិច្ចការផ្ទះរបស់ពួកគេ។ ដូច្នេះហើយទើបក្រុមការងាររបស់គម្រោង មើលឃើញថា នេះជាឱកាសកាន់តែប្រសើរសម្រាប់ពួកគេក្នុងការធ្វើការងារជាមួយនឹងសិស្សបានច្រើន។

កម្មវិធីបណ្តុះបណ្តាលនៅសាលារដ្ឋនេះ ត្រូវបានរៀបចំជាទៀងទាត់ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៨។ បច្ចុប្បន្ននេះ ក្រុមការងារគម្រោង កាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ របស់អាយស៊ីស៊ី បាននិងកំពុងធ្វើវគ្គបណ្តុះបណ្តាលនេះទៅដល់សាលារៀនចំនួន ១៣។ ក្រុមគោលដៅចម្បងរបស់គម្រោង គឺសិស្សសាលាដែលរៀនចាប់ពីថ្នាក់ទី៦រហូតដល់ថ្នាក់ទី៩ ហើយក្នុងពេលបច្ចុប្បន្ននេះពួកគេ កំពុងតែបង្រៀនមុខវិជ្ជាចំនួន៤៖ ១)វិធីសម្គាល់និងកំណត់អត្តសញ្ញាណអ្នកជួញដូរ និងឈ្មួញកណ្តាលដែលនៅពីក្រោយខ្នងការធ្វើ ចំណាកស្រុកខុសច្បាប់ ២)ប្រាក់ និងការចំណាកស្រុក ៣)តម្រូវការនៃការជួញដូរមនុស្ស និង ៤)យេនឌ័រ។ សិស្សានុសិស្សមិនត្រឹម តែអាចទទួលបានចំណេះដឹងពីវគ្គបណ្តុះបណ្តាលរបស់ គម្រោងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ តែប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងអាចចែករំលែកចំណេះដឹងនេះទៅកាន់ក្រុមគ្រួសារ និងមិត្តភក្តិរបស់ពួកគេនៅក្នុងវេទិកាសាធារណៈ និងក្នុងពិធីជប់លៀងក្នុងភូមិផងដែរ។ មុនពេលវគ្គបណ្តុះបណ្តាលនេះ សិស្សខ្លះបានប្រាប់ថាប្រសិនបើពួកគេធ្លាក់វិទ្យាល័យ នោះពួកគេនឹងធ្វើចំណាកស្រុករកការងារធ្វើតែម្តង។ ប៉ុន្តែបន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលនេះមក ពួកគេបាននិយាយថាពួកគេនឹងធ្វើការពិភាក្សាជាមួយ ក្រុមគ្រួសារសិន ហើយនឹងធ្វើការសម្រេចចិត្តដ៏ឆ្លាតវៃថាតើគួរតែធ្វើចំណាកស្រុក ឬក៏អត់។ លើសពីនេះទៀត កម្មវិធីបណ្តុះបណ្តាលនេះ អនុញ្ញាតឲ្យគ្រូបង្រៀននៅសាលារដ្ឋ ទទួលបាននូវចំណេះដឹងបន្ថែមទៀតស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការធ្វើចំណាក ស្រុកខុសច្បាប់ ដែលពួកគាត់អាចចែករំលែកទៅកាន់សិស្សដទៃទៀត នៅពេលដែលគម្រោងត្រូវបានបញ្ចប់។

គម្រោងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ របស់អាយស៊ីស៊ី មានមោទនភាពខ្លាំងណាស់ដែលបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនឹងមន្ទីរអប់រំខេត្ត និងសាលារដ្ឋជាច្រើននៅក្នុងស្រុកព្រះស្តេច។ ការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសាលារដ្ឋ សម្រាប់វគ្គបណ្តុះបណ្តាលបន្ថែមនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សុវត្ថិភាពរបស់សិស្សានុសិស្ស ក៏ដូចជាការបង្កើនការយល់ដឹងអំពីការជួញ ដូរមនុស្ស និងការធ្វើចំណាកស្រុកខុសច្បាប់។

កាលបរិច្ឆេទ៖ កុម្ភៈ ២០១៩